# ការចូលរួមរបស់ដើមបណ្តឹងរដ្ឋប្បវេណីក្នុងអង្គជំនុំជម្រះវិសាមញ្ញ ក្នុងតុលាការកម្ពុជា ៖ សេចក្តីសន្និដ្ឋាន

**ដោយ ម៉ៃឃឹល សាលីបា**

**ថ្ងៃទី៦ ខែវិច្ឆិកា ឆ្នាំ២០០៩**

*ប្រែសម្រួលដោយ ទែន សុខស្រីនិត*

អង្គជំនុំជម្រះសេចក្តីប្រឆាំងនឹង កាំង ហ្គេកអ៊ាវ (ហៅ ឌុច) នៅឯអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា (អ.វ.ត.ក) ពិតជាមានសារសំខាន់ណាស់ ព្រោះថា ឌុច គឺជាមេដឹកនាំខ្មែរក្រហមដំបូងគេបង្អស់ដែលបានប្រឈមមុខចំពោះតុលាការនេះ និងជាប្រជាជនកម្ពុជាម្នាក់ដែលត្រូវទទួលខុសត្រូវសម្រាប់ឧក្រិដ្ឋកម្មដែលបានប្រព្រឹត្តនៅក្នុងអំឡុងរបបកម្ពុជាប្រជាធិបតេយ្យ ។ ប៉ុន្តែ អ្វីដែលប្រហែលជាមានសារសំខាន់បំផុតសម្រាប់ អ.វ.ត.ក នោះ គឺការចូលរួមពីសំណាក់ជនរងគ្រោះដែលជាដើមបណ្តឹងរដ្ឋប្បវេណី ។ អ.វ.ត.ក គឺជាតុលាការអន្តរជាតិដំបូងគេដែលបានអនុញ្ញាតឲ្យមានការចូលរួមដ៏មានសារសំខាន់ពីសំណាក់ជនរងគ្រោះនៅក្នុងដំណើរការនីតិវិធីព្រហ្មទណ្ឌជាផ្លូវការ ។ ចំណាប់អារម្មណ៍ជាច្រើនបានយកចិត្តទុកដាក់ទៅលើគំរូនៃការចូលរួមរបស់ដើមបណ្តឹងរដ្ឋប្បវេណី ពីព្រោះកាលណាមានការកែប្រែលើសិទ្ធិចូលរួមរបស់ដើមបណ្តឹងរដ្ឋប្បវេណី នោះគំរូមួយនេះនឹងមិនត្រឹមតែប៉ះពាល់ដល់ការចូលរួមរបស់ដើមបណ្តឹងរដ្ឋប្បវេណីសម្រាប់សំណុំរឿងផ្សេងទៀតនោះទេ ប៉ុន្តែវាក៏អាចនឹងមានផលប៉ះពាល់យ៉ាងធំធេងលើជនរងគ្រោះរបស់តុលាការព្រហ្មទណ្ឌអន្តរជាតិនេះ និងតុលាការអន្តរជាតិផ្សេងទៀត ដែលធ្វើការជំនុំជម្រះសេចក្តីពីបទឧក្រិដ្ឋនៃអំពើសាហាវឃោរឃៅដូចជា អំពើប្រល័យពូជសាសន៍ ឧក្រិដ្ឋកម្មប្រឆាំងនឹងមនុស្សជាតិ និងឧក្រិដ្ឋកម្មសង្គ្រាម ។

## មូលដ្ឋានលក្ខន្តិកៈស្តីពីការចូលរួមរបស់ដើមបណ្តឹងរដ្ឋប្បវេណី

ការចូលរួមរបស់ជនរងគ្រោះ ឬដើមបណ្តឹងរដ្ឋប្បវេណីនៅក្នុងដំណើរនីតិវិធីព្រហ្មទណ្ឌនេះ គឺជាគំនិតមួយដែលថ្មីស្រឡាងសម្រាប់មេធាវីជាច្រើនរូបដែលអនុវត្តការងារតាមប្រព័ន្ធច្បាប់ខមិនឡ (Common Law) ដូចជាសហរដ្ឋអាមេរិកជាដើម ។ នៅក្នុងប្រព័ន្ធច្បាប់ខមិនឡ អង្គជំនុំជម្រះពីបទព្រហ្មទណ្ឌមួយត្រូវបានរៀបចំឡើងដោយឯករាជ្យពីតុលាការស៊ីវិលមួយ ដែលជនរងគ្រោះនៃបទព្រហ្មទណ្ឌនោះ

ព្យាយាមស្វែងរកសំណងថ្លៃខូចខាតពីជនដៃដល់ដែលរងបទចោទប្រកាន់ ។ បន្ថែមលើនេះ ជនរងគ្រោះត្រូវតែអះអាងការចោទប្រកាន់របស់ខ្លួន ដោយភស្តុតាងជាច្រើនប្រភេទនៅក្នុងតុលាការស៊ីវិល បើប្រៀបធៀបនឹងតុលាការព្រហ្មទណ្ឌ ដែលទាមទារឲ្យមានការផ្ដល់ភស្តុតាងដាក់បន្ទុកចាំបាច់ជាងនេះ ។ ស្របពេលជាមួយគ្នានេះដែរ ព្រះរាជអាជ្ញាត្រូវតែបង្ហាញពីការចោទប្រកាន់របស់ជនរងគ្រោះ ដោយផ្ដល់ភស្តុតាងដាក់បន្ទុកឲ្យលើសពីវិមតិសង្ស័យ ។ ការធ្វើបែបនេះ តែងតែបង្កើតជាទិដ្ឋភាពមិនសមហេតុផលមួយដែលជនរងគ្រោះអាចឈ្នះក្ដីហើយទទួលបានប្រាក់សំណងថ្លៃខូចខាត ស្របពេលនោះដែរ ជនត្រូវចោទក៏អាចរួចផុតពីបទចោទប្រកាន់នៅក្នុងតុលាការព្រហ្មទណ្ឌ ។ (ប្រហែលជាលទ្ធផលនៃរឿងក្ដីគំរូដ៏ល្បីល្បាញបំផុត ទាក់ទិននឹងសេចក្ដីសម្រេចរបស់អង្គជំនុំជម្រះរបស់តុលាការព្រហ្មទណ្ឌ និងតុលាការស៊ីវិលនៅសហរដ្ឋអាមេរិក គឺរឿងក្ដីប្រឆាំងនឹង អូ.ជេ. ស៊ីមស៊ុន ដែលបានសម្លាប់ប្រពន្ធដើមរបស់ខ្លួន គឺ នីគូល ប្រោន ស៊ីមស៊ុន និងមិត្តភក្ដិរបស់នាង រូណាល់ ហ្គូលមែន) ។

ខុសពីប្រព័ន្ធច្បាប់ខំមិនឡូវ៍ ដែលជនរងគ្រោះនៃបទឧក្រិដ្ឋត្រូវតែទាមទារនូវសំណងថ្លៃខូចខាត នៅក្នុងតុលាការស៊ីវិលជាជាងតុលាការព្រហ្មទណ្ឌនោះប្រព័ន្ធច្បាប់ស៊ីវិលឡូ (Civil Law) បានអនុញ្ញាតឲ្យជនរងគ្រោះនៃបទឧក្រិដ្ឋចូលរួមនៅក្នុងដំណើរការនីតិវិធី ដែលតុលាការនឹងផ្ដល់សំណងថ្លៃខូចខាតដល់ជនរងគ្រោះ ។ លើសពីនេះ ដើមបណ្ដឹងរដ្ឋប្បវេណីទទួលបានសិទ្ធិនីតិវិធីជាច្រើន និងតួនាទីសំខាន់មួយនៅក្នុងដំណើរការនីតិវិធីព្រហ្មទណ្ឌ ។ ជាក់ស្ដែង ច្បាប់នីតិវិធីរបស់ អ.វ.ត.ក គឺផ្អែកទៅលើច្បាប់របស់កម្ពុជា ដែលទទួលឥទ្ធិពលយ៉ាងច្រើនពីប្រព័ន្ធច្បាប់ស៊ីវិលឡូវ៍ របស់ប្រទេសបារាំង ។ លក្ខន្តិកៈនៃសិទ្ធិសម្រាប់ជនរងគ្រោះដើម្បីចូលរួមក្នុងដំណើរការនីតិវិធីមានចែងនៅក្នុងវិធានផ្ទៃក្នុងដែលបង្កើតជាប្រភពច្បាប់នីតិវិធីដ៏មានអំណាចនៅក្នុង អ.វ.ត.ក ។

គួរឲ្យចាប់អារម្មណ៍ផងដែរ មិនមានបទបញ្ញត្តិណាមួយត្រូវបានធ្វើឡើងទាំងនៅក្នុងច្បាប់ អ.វ.ត.ក ឬក្នុងសេចក្ដីព្រមព្រៀងរវាងអង្គការសហប្រជាជាតិ និងរាជរដ្ឋាភិបាលកម្ពុជាស្ដីពីការបង្កើត អ.វ.ត.ក ដែលចែងពីសិទ្ធិ និងភាពចាំបាច់របស់ជនរងគ្រោះនោះទេ ។ អគ្គរាជទូត ដេវីដ សេហ្វុហ្វ៊ ដែលជាស្ថាបនិកដឹកនាំមួយរូបរបស់តុលាការកម្ពុជាបានពន្យល់ថា "ក្នុងអំឡុងឆ្នាំ១៩៩០ និងក្នុងដំណាក់កាលតានតឹងបំផុតនៃកិច្ចចរចាស្ដីពីច្បាប់ អ.វ.ត.ក ការពិភាក្សាពីសិទ្ធិរបស់ជនរងគ្រោះមិនត្រូវបានធ្វើឡើងឡើយ ។ ក្នុងដំណាក់កាលដំបូង សិទ្ធិចូលរួមរបស់ដើមបណ្ដឹងរដ្ឋប្បវេណីទំនងដូចជាចម្លែក ប៉ុន្តែតុលាការអាចគោរពតាមសិទ្ធិចូលរួមដើមបណ្ដឹងរដ្ឋប្បវេណីបាន លុះត្រាតែភ្ជាប់ងារសិទ្ធិមនុស្សសម្រាប់កិច្ចការសង្គម

ស៊ីវិលធ្វើការគាំទ្រជនរងគ្រោះនៅក្នុងតុលាការព្រហ្មទណ្ឌតាមច្បាប់នីតិវិធីព្រហ្មទណ្ឌរបស់កម្ពុជា ។ ប៉ុន្តែការជម្រុញឲ្យមានសិទ្ធិចូលរួម ជនរងគ្រោះបានរង់ចាំសេចក្តីព្រាងរបស់វិធានផ្ទៃក្នុងដែលសម្រេចដោយចៅក្រម ហើយដែលត្រូវបានបន្តពិនិត្យដោយការសិក្សាដ៏យកចិត្តទុកដាក់ជាច្រើនទៀតពីសំណាក់អ្នកជំនាញ និងអង្គការក្រៅរដ្ឋាភិបាលទាក់ទិនពីកិច្ចការអ្វីខ្លះដែលអាចធ្វើ និងគួរធ្វើដើម្បីបែងវិធានផ្ទៃក្នុងទាំងនោះពីសិទ្ធិរបស់ជនរងគ្រោះ ។

តាមវិធានផ្ទៃក្នុង ជនទាំងឡាយណាដែលទទួលរងគ្រោះថ្នាក់ផ្នែកសតិអារម្មណ៍ សម្ភារៈ និងផ្នែករូបរាងកាយដែលបណ្តាលមកពីបទឧក្រិដ្ឋដោយផ្ទាល់ នឹងត្រូវទទួលបានសិទ្ធិឲ្យចូលរួមក្នុងដំណើរការនីតិវិធីក្នុងនាមជាដើមបណ្តឹងរដ្ឋប្បវេណី ។ ក្នុងសមាសភាពជាដើមបណ្តឹងរដ្ឋប្បវេណី ជនរងគ្រោះទទួលបានសិទ្ធិចូលរួមនៅក្នុងដំណើរការនីតិវិធីព្រហ្មទណ្ឌប្រឆាំងនឹងជនត្រូវចោទ ដោយទទួលបានការគាំទ្រពីព្រះរាជអាជ្ញា ។ ការចូលរួមនេះរួមមានវត្តមានពេញទីក្នុងអំឡុងដំណើរការអង្គជំនុំជម្រះ និងដំណើរការអង្គបុរេជំនុំជម្រះខណៈពេលដែលរឿងក្តីកំពុងតែត្រូវបានពិនិត្យពិច័យដោយសហចៅក្រមស៊ើបអង្កេត ។ ឧទាហរណ៍ ដើមបណ្តឹងរដ្ឋប្បវេណីអាចស្នើសុំឲ្យសហចៅក្រមស៊ើបអង្កេតធ្វើសកម្មភាពណាដែលចាំបាច់សម្រាប់រៀបចំដំណើរការស៊ើបអង្កេតបាន ។

ជាមួយគ្នានេះ ដើមបណ្តឹងរដ្ឋប្បវេណីក៏អាចទាមទារនូវសំណងខូចខាតផ្នែកសីលធម៌ ឬសំណងខូចខាតរួម ។ តុលាការអាចនឹងផ្តល់នូវ“ទម្រង់នៃសំណងខូចខាតដែលមានលក្ខណៈសមរម្យ” ជូនដល់ជនរងគ្រោះបាន ។ កាលពីថ្ងៃទី១៧ ខែកញ្ញា ឆ្នាំ២០០៩ ក្រុមមេធាវីដើមបណ្តឹងរដ្ឋប្បវេណីទាំងបួនក្រុមក្នុងអង្គជំនុំជម្រះសេចក្តី ឌុច បានធ្វើសេចក្តីសន្និដ្ឋានស្តីពីសំណងខូចខាតរួមមាន ៖ ១) ការចងក្រង និងការផ្សព្វផ្សាយការសុំទោសរបស់ឌុច ២) ការទទួលបាននូវការថែទាំសុខភាពផ្លូវកាយ និងផ្លូវចិត្តដោយឥតគិតថ្លៃ ៣) ការបង្កើតឲ្យមានកម្មវិធីអប់រំពីឧក្រិដ្ឋកម្មដែលបានកើតមានឡើងក្នុងរបបខ្មែរក្រហមដល់ប្រជាជន ៤) ការកសាងបូជនីយដ្ឋានដើម្បីចងចាំជនរងគ្រោះ និង៥) ការបោះពុម្ពសៀវភៅឈ្មោះដើមបណ្តឹងរដ្ឋប្បវេណីទាំងអស់នៅក្នុងសាលក្រមស្ថាពរ ។ តាមវិធានផ្ទៃក្នុងរាល់សំណងខូចខាតទាំងអស់ គឺជាការទទួលរ៉ាប់រងរបស់ជនត្រូវចោទ ។ យ៉ាងណាមិញ នៅក្នុងការសេចក្តីសន្និដ្ឋាននោះដើមបណ្តឹងរដ្ឋប្បវេណីទាំងអស់បានអះអាងថា ប្រសិនបើជនត្រូវចោទមិនអាចរ៉ាប់រងលើប្រាក់សំណងខូចខាតបានទេ នោះតុលាការគួរតែធានាឲ្យបានថា រាជរដ្ឋាភិបាលកម្ពុជា ឬអង្គភាពជនរងគ្រោះអាចផ្តល់សំណងនោះបាន (បើទោះបីជាគ្មានបទបញ្ញត្តិណាមួយបានចែងដូច្នេះនៅក្នុងវិធានផ្ទៃក្នុងក៏

ដោយ) ។ សំខាន់ជាងនេះ គឺវាអាស្រ័យលើចៅក្រមក្នុងការសម្រេចថា តើសំណងថ្លៃខូចខាតដែលបានស្នើសុំនោះមានលក្ខណៈសមរម្យនិងតើតុលាការអាចនឹងជម្រុញឲ្យភ្នាក់ងារផ្សេងទៀតផ្តល់នូវសំណងថ្លៃខូចខាតនេះឬយ៉ាងណា ប្រសិនបើ ឌុច មិនអាច រ៉ាប់រងលើប្រាក់សំណងទាំងនោះ ។

## សកម្មភាពចូលរួមរបស់ដើមបណ្តឹងរដ្ឋប្បវេណី

បើទោះបីជាវិធានផ្ទៃក្នុង បានចែងពីមូលដ្ឋានលក្ខន្តិកៈស្តីពីការចូលរួមរបស់ដើមបណ្តឹងរដ្ឋប្បវេណីក៏ដោយ ក៏វិធានទាំងនោះនៅមានលក្ខណៈទូលាយនៅឡើយ ដូច្នេះវិធានជាក់លាក់ដើម្បីត្រួតពិនិត្យការចូលរួមរបស់ដើមបណ្តឹងរដ្ឋប្បវេណីត្រូវតែជម្រាបជូនដោយសេចក្តីសម្រេចរបស់តុលាការ ។ ចាប់តាំងពីដំណាក់កាលដំបូងនៃអង្គជំនុំជម្រះសេចក្តីប្រឆាំងនឹង ឌុច ការកំណត់ជាក់លាក់ពីការចូលរួមរបស់ដើមបណ្តឹងរដ្ឋប្បវេណីកំពុងតែដំណើរការទៅមុខនៅឡើយ ពីព្រោះថា តុលាការត្រូវតែដោះស្រាយជាមួយនឹងបញ្ហាដែលកើតឡើងជាបន្តបន្ទាប់ទាក់ទិននឹងដើមបណ្តឹងរដ្ឋប្បវេណីដូចជា : ១) វិធីសាស្ត្រគ្រប់គ្រងវត្តមានចូលរួមរបស់ដើមបណ្តឹងរដ្ឋប្បវេណីជាច្រើននាក់ និងមេធាវីដើមបណ្តឹងរដ្ឋប្បវេណីទាំងបួនក្រុម ២) សេចក្តីជំទាស់របស់មេធាវីការពារក្តី ក្នុងការមិនទទួលស្គាល់ពាក្យស្នើសុំរបស់ដើមបណ្តឹងរដ្ឋប្បវេណីចំនួន២៨រូប ខណៈពេលដែលអង្គជំនុំជម្រះបាននឹងជិតបញ្ចប់ដំណើរការរបស់ខ្លួន និង៣) សេចក្តីសម្រេចរបស់អង្គជំនុំជម្រះសាលាដំបូង ក្នុងការមិនអនុញ្ញាតឲ្យមេធាវីដើមបណ្តឹងរដ្ឋប្បវេណីធ្វើសាណាឆ្លើយតបនឹងការផ្តន្ទាទោស ឬសួរសាក្សីអត្តចរិក និងការកើតឡើងនូវពហិការមិនចូលរួមដំណើរការនីតិវិធីរបស់ដើមបណ្តឹងរដ្ឋប្បវេណី ។

ដោយសារតែនេះគឺជាលើកដំបូងសម្រាប់តុលាការ ដែលអនុញ្ញាតឲ្យមានការចូលរួមដ៏សំខាន់ពីសំណាក់ដើមបណ្តឹងរដ្ឋប្បវេណី ដូច្នេះហើយបានជាតុលាការខ្មែរក្រហមនេះ បានប្រឈមមុខនឹងបញ្ហាជាច្រើនក្នុងការគ្រប់គ្រងវត្តមានរបស់ដើមបណ្តឹងរដ្ឋប្បវេណីទាំងអស់ ។ ដំបូង ដើមបណ្តឹងរដ្ឋប្បវេណីទាំងអស់ត្រូវបានបំបែកជាបួនក្រុមដាច់ដោយឡែកពីគ្នា ដោយក្នុងក្រុមនីមួយៗមានមេធាវីជាតិម្នាក់ និងអន្តរជាតិម្នាក់ ។ បន្ថែមលើនេះដើមបណ្តឹងរដ្ឋប្បវេណីមិនបានដាក់ឲ្យស្ថិតក្នុងក្រុមជាមួយគ្នាដោយវិធីសាស្ត្រសមហេតុផលនោះទេ (ដូចជា តាមប្រភេទជនរងគ្រោះ ឬប្រភេទនៃការរងគ្រោះថ្នាក់ជាដើម) ។ ផ្ទុយទៅវិញ ក្រុមដើមបណ្តឹងរដ្ឋប្បវេណីទាំងបួនក្រុមនេះកើតឡើងដោយសារតែអង្គការអន្តរការីខុសៗគ្នាជួយជ្រើសរើសពាក្យស្នើសុំធ្វើជាដើមបណ្តឹងរដ្ឋវេណីតែប៉ុណ្ណោះ ហើយអង្គការទាំងនោះចង់ធ្វើជា

តំណាងឲ្យក្រុមជនរងគ្រោះរបស់ខ្លួនដាច់ដោយឡែកពីគ្នា ។ មូលហេតុបែបនេះមិនត្រឹមតែបង្កឲ្យមានបញ្ហាទាក់ទិននឹងការធ្វើជាតំណាងឲ្យមានលក្ខណៈស៊ីចង្វាក់គ្នាតែប៉ុណ្ណោះទេ ប៉ុន្តែថែមទាំងបង្កឲ្យមានផលប៉ះពាល់ដោយអចេតនា ដែលពន្យារដំណើការនីតិវិធីរបស់តុលាការអស់រយៈពេលយ៉ាងយូរមកហើយ ។

ជាឧទាហរណ៍ ដើមបណ្តឹងរដ្ឋប្បវេណីបានអនុញ្ញាតឲ្យសួរសំណួរសាក្សីជាច្រើននាក់ ។ នេះមានន័យថា បើទោះបីជាកម្រកើតមានឡើងក៏ដោយ ក៏នៅក្នុង អ.វ.ត.ក សាក្សីម្នាក់អាចនឹងត្រូវបានចោទសួរដោយមេធាវី ១៨រូបខុសៗគ្នាមុននឹងអាចបញ្ចប់កសិណសាក្សីរបស់ខ្លួនបាន ។ (សាក្សីអាចនឹងត្រូវបានចោទសួរដោយចៅក្រម៥រូប សហព្រះរាជអាជ្ញាជាតិ និងអន្តរជាតិ មេធាវីដើមបណ្តឹងរដ្ឋប្បវេណីចំនួន៨រូប មេធាវីការពារក្តីជាតិ និងអន្តរជាតិ ហើយពេលខ្លះដោយមេធាវីរបស់ដើមបណ្តឹងរដ្ឋប្បវេណីផ្ទាល់ផងដែរ) ។ បើទោះបីជាវាដូចជាអយុត្តិធម៌ក្នុងការដាក់កំហុសតែលើដើមបណ្តឹងរដ្ឋប្បវេណីក៏ដោយ ក៏ស្របពេលជាមួយគ្នានេះដើមបណ្តឹងរដ្ឋប្បវេណីទាំងអស់អាចមានចំនួនទ្វេរដង ព្រោះថាមានមេធាវីច្រើនគួរសមដែលដាក់ឲ្យធ្វើការជាក្រុមជាមួយគ្នានៅក្នុងអង្គសវនាការ ដែលមានចំនួនច្រើនជាងមេធាវីការពារក្តី និងព្រះរាជអាជ្ញា ។ លើសពីនេះទៅទៀត ការខ្វះខាតការសម្របសម្រួលគ្នារវាងក្រុមដើមបណ្តឹងរដ្ឋប្បវេណីជាញឹកញាប់បណ្តាលឲ្យមានការចោទសួរមិនសំខាន់ ។ អង្គជំនុំជម្រះបានធ្វើការឆ្លើយតបនឹងបញ្ហានេះដោយកំណត់ពេលវេលាសួរសំណួររបស់ដើមបណ្តឹងរដ្ឋប្បវេណី (ដោយផ្តល់ពេលវេលាសម្រាប់សួរសាក្សីតិចជាងមេធាវីការពារក្តី និងព្រះរាជអាជ្ញា) ។ សំខាន់ជាងនេះ ភាគីទាំងអស់បានទទួលស្គាល់ថា ការបែងចែកក្រុមដើមបណ្តឹងរដ្ឋប្បវេណីជាបួនក្រុមដាច់ដោយឡែកពីគ្នានេះបានចោទជាបញ្ហាមួយ ហើយនឹងមិនអាចរក្សាទុកការបែងចែកនេះសម្រាប់រឿងក្តីបន្ទាប់ទៀតដែរ ពីព្រោះថា ពេលវេលាជាច្រើនត្រូវបានផ្តល់ឲ្យដើមបណ្តឹងរដ្ឋប្បវេណី ។

បញ្ហាចម្បងទីពីរសម្រាប់តុលាការដើម្បីដោះស្រាយនោះគឺ សេចក្តីជំទាស់របស់មេធាវីការពារក្តីក្នុងការមិនទទួលស្គាល់ពាក្យស្នើសុំរបស់ដើមបណ្តឹងរដ្ឋប្បវេណីចំនួន២៨រូប ខណៈពេលដែលអង្គជំនុំជិតបានបញ្ចប់ទៅហើយ ។ ដើម្បីទទួលស្គាល់ជាដើមបណ្តឹងរដ្ឋប្បវេណី ជនរងគ្រោះត្រូវតែដាក់សេចក្តីសន្និដ្ឋានជូនអង្គភាពជនរងគ្រោះមុនអង្គជំនុំជម្រះចាប់ផ្តើមដំណើរការ ។ ស្របពេលជាមួយគ្នានោះ សេចក្តីសន្និដ្ឋាននេះ អាចនឹងត្រូវបានត្រួតពិនិត្យដោយសហចៅក្រមស៊ើបអង្កេតដែលអាចមានសិទ្ធិបដិសេធមិនទទួលយកពាក្យស្នើសុំធ្វើជាដើមបណ្តឹងរដ្ឋប្បវេណីរបស់ជនរងគ្រោះបានតាមរយៈដីកាជាលាយល័ក្ខអក្សរដល់សាលាឧទ្ធរណ៍ ។ ដំណើរការដាក់ពាក្យស្នើសុំធ្វើជាដើមបណ្តឹងរដ្ឋប្បវេណីនេះ មានចំនួនកើនដល់

១០០ដើមបណ្តឹងរដ្ឋប្បវេណី ខណៈពេលដែលអង្គជំនុំជម្រះចាប់ផ្តើមដំណើរការ ។ យ៉ាងណាមិញ ប៉ុន្មានសប្តាហ៍មុននឹងការបញ្ចប់ដំណើរការបញ្ជាក់ពីភស្តុតាង អង្គជំនុំជម្រះសាលាដំបូងបានទទួលយកសេចក្តីជំទាស់របស់មេធាវីការពារក្តី ក្នុងការមិនទទួលស្គាល់ពាក្យស្នើសុំរបស់ដើមបណ្តឹងរដ្ឋប្បវេណីចំនួន ២៤រូប ដោយហេតុផលថា ពាក្យស្នើសុំទាំងនោះមិនមានភស្តុតាងគ្រប់គ្រាន់ដើម្បីបញ្ជាក់ថា អ្នកដាក់ពាក្យស្នើសុំទាំង២៤រូបនោះពិតជាជនរងគ្រោះ ។

បញ្ហាបន្តទៀតនោះ គឺសំណួរទាក់ទិននឹងពាក្យស្នើសុំដាក់លាក់ណាមួយ ។ វាច្បាស់ដណាស់ថា មានពាក្យស្នើសុំខ្លះមិនមានលក្ខណៈពេញលេញនៅឡើយទេ ពីព្រោះឯកសារដែលជាប់ពាក់ព័ន្ធមិនទាន់បានប្រមូលឬជាទូទៅគឺដោយសារតែឯកសារទាំងនោះបានបាត់បង់ ។ ការអនុវត្តទាំងស្រុងមានសំណួរចោទសួរថា ៈ តើដំណើរស៊ើបសួរដែលរួមមានភាគីជាច្រើនផ្សេងៗគ្នាដូចជា ពីអង្គភាពជនរងគ្រោះទៅសហចៅក្រមស៊ើបអង្កេត និងទៅមេធាវីដើមបណ្តឹងរដ្ឋប្បវេណី មេធាវីការពារក្តី និងអង្គជំនុំជម្រះសាលាដំបូងនេះ អាចផ្តល់លទ្ធផលជាភាគរយខ្ពស់បានយ៉ាងដូចម្តេច ចំពោះពាក្យស្នើសុំដែលមានលក្ខណៈមិនពេញលេញ ហើយដែលត្រូវបានបដិសេធទទួលស្គាល់រហូតដល់ប៉ុន្មានសប្តាហ៍ចុងក្រោយនៃអង្គជំនុំជម្រះនោះ?

នៅថ្ងៃជាមួយគ្នានេះដែរ អង្គជំនុំជម្រះបានស្តាប់សេចក្តីជំទាស់របស់មេធាវីការពារក្តីពីពាក្យស្នើសុំធ្វើជាដើមបណ្តឹងរដ្ឋប្បវេណី ។ ក្រោយមកចៅក្រមបានចេញសេចក្តីសម្រេចផ្ទាល់ថា មេធាវីដើមបណ្តឹងរដ្ឋប្បវេណីមិនអនុញ្ញាតឲ្យធ្វើសាណាឆ្លើយតបនឹងការផ្តន្ទាទោសជនត្រូវចោទទេ ។ ស្របពេលជាមួយគ្នានេះ អង្គជំនុំជម្រះបានស្តាប់ពីការអះអាងប្រឆាំងដ៏ក្តៅគគុកទាក់ទិននឹងបញ្ហាថា តើមេធាវីដើមបណ្តឹងរដ្ឋប្បវេណីគួរ ឬមិនគួរអនុញ្ញាតឲ្យចោទសួរសាក្សីអត្តចរិក ។ មេធាវីដើមបណ្តឹងរដ្ឋប្បវេណីបានអះអាងថា វិធានផ្ទៃក្នុងផ្សេងទៀតបានចែងពីសិទ្ធិចូលរួមយ៉ាងពេញលេញរបស់ដើមបណ្តឹងរដ្ឋប្បវេណី និងមិនបានបែងចែកភាពខុសប្លែកគ្នារវាងសាក្សីអត្តចរិក និងសាក្សីធម្មតានោះទេ ។ នៅក្នុងកិច្ចឆ្លើយតបរបស់ខ្លួន មេធាវីការពារក្តីបានធ្វើការអះអាងដោយផ្អែកលើសេចក្តីសម្រេចដែលបានប្រកាសកាលពីពេលថ្មីៗនេះថា ភស្តុតាងរបស់សាក្សីអត្តចរិកមានជាប់ពាក់ព័ន្ធផ្ទាល់នឹងការផ្តន្ទាទោសជនត្រូវចោទ ហើយមិនមានជាប់ពាក់ព័ន្ធនឹងបញ្ហាទោសកំហុស ភាពឈឺចាប់ និងការរងទុក្ខវេទនារបស់ដើមបណ្តឹងរដ្ឋប្បវេណី ឬក៏ទាក់ទងនឹងសំណងថ្លៃខូចខាតឡើយ ។ នាពេលបញ្ចប់អង្គជំនុំជម្រះសម្រាប់ថ្ងៃនេះ អង្គជំនុំជម្រះសាលាដំបូងបានចេញសេចក្តីសម្រេចតាមសម្លេងគាំទ្របួនលើមួយ (ដូចគ្នានឹងករណីសេចក្តីសម្រេចនីតិវិធីកាលពីមុន) ថា ដើមបណ្តឹងរដ្ឋប្បវេណីមិនត្រូវបានអនុញ្ញាតឲ្យចោទសួរសាក្សីអត្តចរិកទេ ។

មុននឹងអង្គជំនុំជម្រះនៅថ្ងៃបន្ទាប់បានចាប់ផ្តើម ដើមបណ្តឹងរដ្ឋប្បវេណីបានប្រកាសពហិការមិនចូលរួមដំណើរការនីតិវិធី ក្នុងអំឡុងការផ្តើកសិណសាក្សីរបស់សាក្សីអត្តចរិកដែលនៅសល់នោះទេ ។ នៅថ្ងៃនោះ ដើមបណ្តឹងរដ្ឋប្បវេណីទាំងអស់ បាននាំគ្នាទៅគោរពវិញ្ញាណក្ខ័ណ្ឌអ្នកដែលបាត់បង់ជីវិតនៅគុកទួលស្លែង ប៉ុន្តែអ្នកទាំងអស់នោះមិនអាចលាក់បាំងនូវអារម្មណ៍ភ្ញាក់ផ្អើលនិងការខកចិត្តដែលបង្ហាញឲ្យឃើញយ៉ាងច្បាស់នៅលើទឹកមុខរបស់គេបានឡើយ ។ ដើមបណ្តឹងរដ្ឋប្បវេណីយល់ថា សិទ្ធិរបស់ខ្លួនត្រូវបានដាក់កម្រិតជ្រុលហួសហេតុដែលថា តុលាការមិនមានបំណងស្តាប់នូវអ្វីដែលដើមបណ្តឹងរដ្ឋប្បវេណីជឿថាជាពាក្យបណ្តឹងត្រឹមត្រូវតាមផ្លូវច្បាប់នោះទេ ។ នៅក្នុងសេចក្តីសម្រេចជាលាយល័ក្ខអក្សរសមហេតុផលដែលបានចេញអស់រយៈពេលជិតមួយខែកន្លះហើយនោះ អង្គជំនុំជម្រះសាលាដំបូងបានពន្យល់ប្រាប់ថា តួនាទីរបស់ដើមបណ្តឹងរដ្ឋប្បវេណី ត្រូវបានដាក់កម្រិតក្នុងការទាមទារនូវសំណងថ្លៃខូចខាតនិងការផ្តល់ជំនួយការដល់ព្រះរាជអាជ្ញា ដើម្បីបង្ហាញថាជនត្រូវចោទមានទោស (ដែលជាជោគជ័យមួយមានសារសំខាន់ដើម្បីទទួលយកបានសំណងខូចខាត) ។ ការផ្តន្ទាទោស និងភស្តុតាងបញ្ជាក់ពីអត្ត-ចរិកជនត្រូវចោទ មិនមានជាប់ពាក់ព័ន្ធសំណងថ្លៃខូចខាត ដូច្នេះ ការផ្តន្ទាទោស និងភស្តុតាងបញ្ជាក់ពីអត្តចរិកជនត្រូវចោទ ត្រូវដាក់ឲ្យនៅក្រៅកិច្ចការរបស់ព្រះរាជអាជ្ញា ។

## ការចូលរួមរបស់ដើមបណ្តឹងរដ្ឋប្បវេណីគំរូក្នុងពេលអនាគត

ក្នុងកិច្ចឆ្លើយតបនឹងបញ្ហាជាច្រើន ដែលលើកឡើងដោយមេធាវីដើមបណ្តឹងរដ្ឋប្បវេណី ទាក់ទិននឹងការចូលរួមយ៉ាងពេញលេញរបស់ដើមបណ្តឹងរដ្ឋប្បវេណីក្នុងអង្គជំនុំជម្រះប្រឆាំងនឹង ឌុច នោះអង្គជំនុំជម្រះបានប្រារព្ធការប្រជុំពេញអង្គលើកទី៦របស់ខ្លួន ដែលបានធ្វើសេចក្តីសម្រេចលើគោលការណ៍សំខាន់មួយចំនួនសម្រាប់ការផ្លាស់ប្តូរលើការចូលរួមរបស់ដើមបណ្តឹងរដ្ឋប្បវេណីនាពេលអនាគត ។ អង្គជំនុំជម្រះបានសម្រេចថា ដើមបណ្តឹងរដ្ឋប្បវេណីទាំងអស់នឹងត្រូវដាក់បញ្ចូលជាក្រុមតែមួយ ដែលនឹងត្រូវធ្វើសេចក្តីអះអាងសម្រាប់សំណងថ្លៃខូចខាតផ្នែកសីលធម៌ និងសំណងថ្លៃខូចខាតរួម ។ ក្រុមដើមបណ្តឹងរដ្ឋប្បវេណីរួមនេះ នឹងមានសហមេធាវីពីររូបធ្វើជាតំណាង ជាជាងតំណាងដោយមេធាវីដើមបណ្តឹងរដ្ឋប្បវេណីច្រើន ។ ការប្រជុំពេញអង្គនេះក៏បានសម្រេចថា ពាក្យស្នើសុំធ្វើជាដើមបណ្តឹងរដ្ឋប្បវេណីទាំងអស់នឹងត្រូវទទួលយក ហើយសេចក្តីជំទាស់មិនទទួលស្គាល់ពាក្យស្នើសុំទាំងអស់នោះត្រូវតែធ្វើឡើងមុនដំណើរការអង្គជំនុំជម្រះសេចក្តីសម្រាប់សំណុំរឿងលេខ០០២ ។ ដើម្បីបន្តធ្វើឲ្យការផ្លាស់ប្តូរចំពោះការចូលរួមរបស់ដើមបណ្តឹងរដ្ឋប្បវេណីប្រកបដោយប្រសិទ្ធិភាព និងស្របតាមគោលការណ៍ទូទៅ ដែលបាន

ព្រមព្រៀងគ្នាដោយការប្រជុំពេញអង្គ នោះការប្រជុំពេញអង្គមួយផ្សេងទៀត ដែលនឹងធ្វើឡើងក្នុងខែមករា ឆ្នាំ២០១០ខាងមុខនេះ នឹងធ្វើការពិចារណាលើការស្នើសុំដាក់លាក់មួយចំនួន និងដាក់ការកែប្រែទាក់នោះចូលក្នុងវិធានផ្ទៃក្នុងដែលទាក់ទិននឹងការចូលរួមរបស់ដើមបណ្តឹងរដ្ឋប្បវេណី ។

## សេចក្តីសន្និដ្ឋាន

ជាសង្ខេប បើទោះបីជាការចូលរួមរបស់ដើមបណ្តឹងរដ្ឋប្បវេណីត្រូវបានដាក់ចូលជាធរមានក្នុងវិធានផ្ទៃក្នុងក៏ដោយ ក៏គំរូដ៏ល្អនៃការអនុញ្ញាតឲ្យមានការចូលរួមរបស់ដើមបណ្តឹងរដ្ឋប្បវេណីកំពុងតែដំណើរការទៅមុខនៅឡើយ ។ ទម្រង់ដើមនៃការចូលរួមរបស់ដើមបណ្តឹងរដ្ឋប្បវេណីដែលមានចែងក្នុងប្រព័ន្ធច្បាប់ស៊ីវិលឡូវរបស់បារាំង និងកម្ពុជាមិនមានលក្ខណៈពេញលេញ ដើម្បីបង្ហាញឲ្យបានច្បាស់ពីធាតុផ្សំនៅក្នុងអង្គជំនុំជម្រះបទឧក្រិដ្ឋអំពើសាហាវឃោរឃៅនៅឡើយទេ ។ ឧទាហរណ៍ តុលាការព្រហ្មទណ្ឌជាធម្មតាអនុញ្ញាតឲ្យការចូលរួមពីសំណាក់ជនរងគ្រោះក្នុងចំនួនតិចតួចបំផុត ប៉ុន្តែអង្គជំនុំជម្រះបទឧក្រិដ្ឋអំពើសាហាវឃោរឃៅ អាចមានការចូលរួមពីជនរងគ្រោះរាប់ពាន់នាក់ ដែលបានជ្រើសរើសឲ្យចូលរួមក្នុងដំណើរការនីតិវិធី ។ ការអនុញ្ញាតបែបនេះអាចក្លាយជាឧបសគ្គដ៏ចម្បងសម្រាប់តុលាការ ហើយអាចមានផលប៉ះពាល់ដោយអចេតនា ដែលពន្យាពេលដំណើរការនីតិវិធីរបស់តុលាការបាន ។ លទ្ធផលបែបនេះបានធ្វើឲ្យតុលាការកាន់តែមានការលំបាក ក្នុងការសម្រេចឲ្យបាននូវយុត្តិធម៌ឲ្យទាន់ពេលវេលា ។ យ៉ាងណាមិញ បើទោះបីជាមានការពន្យាដំណើរការនីតិវិធីរបស់តុលាការក៏ដោយ ក៏អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា បានលើកកម្ពស់សិទ្ធិរបស់ជនរងគ្រោះបានមួយកម្រិត ដែលមិនធ្លាប់មានពីមុនមកនៅក្នុងតុលាការអន្តរជាតិដទៃផ្សេងទៀតឡើយ ។ ការកំណត់លើការចូលរួមរបស់ដើមបណ្តឹងរដ្ឋប្បវេណីគំរូជាបន្តទៀតរបស់តុលាការខ្មែរក្រហមនេះ នឹងជះឥទ្ធិពលដ៏យូរអង្វែងលើតុលាការអន្តរជាតិផ្សេងទៀតដែលប្រព្រឹត្តឡើងនៅក្រៅប្រទេសកម្ពុជា ។